# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់** | : | ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jan-2014, 12:50
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្តីពីការប្រើប្រាស់ភស្តុតាង និងនីតិវិធីក្នុងការកោះហៅសាក្សីជាថ្មី ពីសំណុំរឿង០០២/០១ ទៅក្នុងសំណុំរឿងលេខ០០២/០២

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor Koppe
លោក គង់ សំអុន
លោក Arthur VERCKEN
Anta GUISSE

# សេចក្តីសន្និដ្ឋាន

១- សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង(“អង្គជំនុំជម្រះ”)សម្រេចថា ក) រាល់ភ័ស្តុតាងទាំងអស់ ដែលត្រូវបានទទួលយកនៅក្នុងសំណុំរឿងលេខ០០២/០១ ហើយដែលបានដាក់លេខសម្គាល់ E3 នឹងត្រូវបានចាត់ទុកថា បានដាក់ជូនដោយត្រឹមត្រូវនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរួចហើយ ដើម្បីគោលបំណងឲ្យកិច្ចដំណើរការនីតិវិធីសវនាការនាពេលអនាគត ទាក់ទងនឹងបទចោទប្រកាន់ទាំងឡាយដែលនៅសល់ <u>និង ខ)សាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងឡាយដែលបានស្តាប់ចម្លើយរួចនៅក្នុងសំណុំរឿងលេខ០០២/០១ អាចនឹងត្រូវបានកោះហៅសាជាថ្មីទៀតនៅក្នុងការជំនុំជម្រះលើសំណុំរឿងលេខ០០២/០២ បានតែក្នុងករណីមានភាគីនានាដែលស្នើសុំបំពេញគ្រប់តាមលក្ខខណ្ឌជូនតុលាការថា ការសួរដេញដោលបន្ថែមទៀតគឺដើម្បីផលប្រយោជន៍យុត្តិធម៌ប៉ុណ្ណោះ</u>។ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា ការមានដំណោះស្រាយបឋមមួយលើបញ្ហានេះ គឺជាការសំខាន់ និងចាំបាច់ណាស់ដើម្បីឲ្យមានប្រសិទ្ធភាពដល់ការជំនុំជម្រះក្តីនៃបទចោទប្រកាន់នានាក្នុងសំណុំរឿងលេខ០០២ ដែលនៅសល់។

២- គ្មានភាគីណាមួយ ឬគ្មានអ្នកចូលរួមណាមួយ អាចនឹងមានលទ្ធភាពដាក់ជូននូវបញ្ជីសាក្សី អ្នកជំនាញ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមដែលនឹងត្រូវស្តាប់ចម្លើយ ឬភ័ស្តុតាងជាឯកសារនានាបន្ថែមដើម្បីដាក់បង្ហាញឲ្យបានច្បាស់លាស់នោះទេ[1] បើមិនបានដឹងច្បាស់ថាតើភ័ស្តុតាង-ដែលបានពីការជំនុំជម្រះលើសំណុំរឿងលេខ០០២/០១នោះ នឹងត្រូវបានទទួលយកយ៉ាងដូចម្តេចខ្លះទៅក្នុងសំណុំរឿងលេខ០០២/០២នោះ។ បន្ថែមពីលើនេះការកំណត់សម្រេចណាមួយលើបញ្ហានេះ ក៏អាស្រ័យលើការដាក់សំណើជាលាយលក្ខណ៍អក្សរ និងការលើកអំណះអំណាងដោយផ្ទាល់មាត់របស់ភាគីនានាទាក់ទងទៅនឹងការកំណត់វិសាលភាពនៃសំណុំរឿងលេខ០០២/០២[2]។ ជាងនេះទៅទៀត សេចក្តីសម្រេចលើបញ្ហានេះ គឺជាលក្ខខណ្ឌតម្រូវសម្រាប់ការរៀបចំផែនការបុគ្គលិក និងការរៀបចំហិរញ្ញវត្ថុសម្រាប់ស្ថាប័ន ដោយសារការណ៍នេះនឹងមានផលប៉ះពាល់ទាំងស្រុងទៅលើការវាយតម្លៃដោយការប៉ាន់ប្រមាណអំពីរយៈពេលរំពឹងទុក នៃការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០២/០២។ ករណីបើសិនជាអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចថា ភ័ស្តុតាងដែលមកពីសំណុំរឿងលេខ០០២/០១ ចាំបាច់ត្រូវតែ

---

[1] **E301/5** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ពាក់ព័ន្ធនឹងផែនការការងារសម្រាប់សំណុំរឿង០០២/០២ និងការកំណត់កាលបរិច្ឆេទសម្រាប់ការដាក់ឯកសារនៅពេលខាងមុខ, ២៤ ធ្នូ ២០១៣ ត្រង់កថាខណ្ឌ៣។

[2] ដូចគ្នានឹងខាងលើ ត្រង់កថាខណ្ឌទី៥។

ធ្វើឡើងវិញរដងដែលៗ សម្រាប់សំណុំរឿងលេខ០០២/០២នោះ ការណ៍នេះទំនងជានឹងធ្វើឲ្យពេលវេលាដែលត្រូវការសម្រាប់ជំនុំជម្រះក្តីលើបទចោទនានាដែលនៅសល់ អាចកើនឡើងទ្វេរដង។ ការសម្រេចឲ្យបានឆាប់រហ័សលើបញ្ហានេះ គឺជាលក្ខខណ្ឌតម្រូវចាំបាច់សម្រាប់ការធ្វើសេចក្តីសម្រេចមួយ ដោយបានទទួលនូវពត៌មានគ្រប់ជ្រុងជ្រោយ ទៅនឹងវិសាលភាព និងការកំណត់ពេលវេលានៃសំណុំរឿងលេខ០០២/០២ ដែលជាកម្មវត្ថុនៃការ ធ្វើសវនាការស្តីពីការប្រជុំរៀបចំសវនាការនាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ ខាងមុខនេះ។

## *ក. អង្គជំនុំជម្រះបានយល់ព្រមដោយមិនបាននិយាយឲ្យបានច្បាស់លើសំណើដែលស្នើសុំឲ្យសម្រេច នៅក្នុងសេចក្តីសម្រេចកាលពីមុនៗរបស់ខ្លួន*

៣- ការណ៍ដែលយកភ័ស្តុតាងដែលមានស្រាប់ដែលអាចរកបានដោយស្វ័យប្រវត្តិ ពីក្នុងសំណុំរឿងលេខ០០២/០១ ដើម្បីយកមកប្រើប្រាស់នៅក្នុងសំណុំរឿងលេខ០០២/០២ គឺគ្រាន់តែជាការប៉ាន់ស្មានមួយនៅក្នុងរង្វង់សេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូង រហូតមកដល់ពេលបច្ចុប្បន្ន។ ដូចដែលអង្គជំនុំជម្រះបានបញ្ជាក់យ៉ាងស៊ីសង្វាក់គ្នាហើយថា សំណុំរឿងលេខ០០២/០១ គឺចង់មានន័យថា "ផ្តល់នូវមូលដ្ឋានគ្រឹះមួយសម្រាប់ការពិនិត្យយ៉ាងលម្អិតទៅលើបទចោទដែលនៅសល់ និងការចោទប្រកាន់ខាងអង្គហេតុនានាប្រឆាំងនឹងជនជាប់ចោទ នៅក្នុងការជំនុំជម្រះក្តីជាបន្តបន្ទាប់ទៅទៀត"[3]។ ការធ្វើបែបនេះ ការជំនុំជម្រះក្តីនៅក្នុងវគ្គទីមួយ គឺត្រូវបានរៀបចំឡើង "ដើម្បីបញ្ចូលនៅក្នុងនោះនូវ

[3] ឯកសារលេខ **E124/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខណ្ឌនានានៃដីកាសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី របស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខE124/2) និងសំណើសុំពាក់ព័ន្ធនានាព្រមទាំងឧបសម្ព័ន្ធ, ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ("សេចក្តីសម្រេចស្តីពីការពិចារណាឡើងវិញអំពីលក្ខណ្ឌនានានៃដីកាសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី") ត្រង់កថាខណ្ឌទី១០។ ឯកសារលេខ **E284** សេចក្តីសម្រេចស្តីពី ការបំបែកកិច្ចដំណើរការនីតិវិធី នៃសំណុំរឿងលេខ០០២ បន្ទាប់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី៨ កុម្ភៈ ២០១៣, ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ("សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរ ការនីតិវិធីលើកទីពីរ") ត្រង់កថាខណ្ឌទី១៥។ សូមអានផងដែរ ឯកសារលេខ **E131** ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំរឿងលេខ០០២, ចុះថ្ងៃទី១៨ តុលា២០១១ ត្រង់ទំព័រ២: "ថ្វីដ្បិតដីកាសម្រេចបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ (ឯកសារលេខ E124) បានបំបែកការជំនុំជម្រះជាដំណាក់កាលក្តី ក៏អង្គជំនុំជម្រះរំពឹងថា ដំណាក់កាលជំនុំជម្រះដំបូងនេះ នឹងផ្តល់ជាមូលដ្ឋានរួមមួយសំរាប់បទចោទទាំអស់ រួមទាំងបទចោទនានាដែលអង្គជំនុំជម្រះនឹង លើកយកទៅពិនិត្យក្នុងសវនាការដំណាក់កាលបន្ទាប់។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាត្រូវធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ពាក់ព័ន្ធនឹងគ្រប់រាល់បទចោទ និងការចោទប្រកាន់លើអង្គហេតុទាំងអស់ប្រឆាំងនឹងជនជាប់ចោទដែលមាននៅក្នុងដីកាដំណោះស្រាយ" ។

ការពិនិត្យមើលទាំងស្រុងទៅលើបញ្ហា និងការចោទប្រកាន់នានាដែលជាមូលដ្ឋានគ្រឹះប្រឆាំងនឹងជនជាប់ចោទ”[4]។

៤- ដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យធ្វើការសួរដេញដោលសាក្សីជំនាញនានានៅក្នុងសំណុំរឿងលេខ០០២/០១ ដើម្បីរួមបញ្ចូលក្នុងនោះនូវបញ្ហាទាំងឡាយដែលទាក់ទងនឹងបទចោទនានាដែលនឹងត្រូវបានលើកឡើងតែនៅក្នុងការជំនុះជម្រះក្ដីក្រោយៗទៀតតែប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សាក្សីជំនាញទាំងឡាយ “អាចត្រូវសួរដេញដោលបានលើគ្រប់រាល់បញ្ហាទាំងអស់ដែលខ្លួនដឹង ឬលើចំណេះដឹងជំនាញទាក់ទងនឹងដីកាដំណោះស្រាយក្នុង សំណុំរឿងលេខ០០២ទាំងមូល”[5]។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យភាគីនានា អាចសួរដេញដោលសាក្សីដែលមានវ័យចំណាស់នានា លើរាល់បញ្ហាទាំងអស់ដែលមាននៅក្នុងវិសាលភាពនៃសំណុំរឿងលេខ០០២[6]។

៥- ភស្តុតាងនៅក្នុងសំណុំរឿងលេខ០០២/០១នោះ ដែលនឹងត្រូវយកទៅប្រើប្រាស់ដោយផ្ទាល់នៅក្នុងការជំនុំជម្រះក្ដីនានាក្នុងពេលអនាគត ក៏បង្ហាញជាក់ស្ដែងនៅក្នុង “ផ្នែកជាបណ្ដោះអាសន្ន”[7] សម្រាប់ការជំនុំជម្រះក្ដីនាពេលអនាគត ដែលអង្គជំនុំជម្រះសាលាដំបូងបានដាក់បញ្ចូលនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីជាថ្មីឡើងវិញ លើសំណុំរឿងលេខ០០២/០១។ ដោយហេតុថា សំណុំរឿងលេខ០០២/០១ បានរួមបញ្ចូលនៅក្នុងនោះនូវកថាខណ្ឌនានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទងនឹងបញ្ហាជាមូលដ្ឋាន តួយ៉ាងដូចជា ប្រវត្តិដើមរបស់កម្ពុជាប្រជាធិបតេយ្យ

---

[4] ឯកសារលេខ **E124/7** សេចក្ដីសម្រេចស្ដីពីការពិចារណាឡើងវិញអំពីលក្ខណ្ឌនានានៃដីកាសម្រេចស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី, កំណត់សម្គាល់លេខ៤ *ខាងដើម* ត្រង់កថាខណ្ឌទី១០។ ឯកសារលេខ **E284** សេចក្ដីសម្រេចស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ, កំណត់សម្គាល់លេខ៤ *ខាងដើម* ត្រង់កថាខណ្ឌទី១៥។

[5] ឯកសារលេខ**E215** សេចក្ដីសម្រេចលើការចាត់តាំងអ្នកជំនាញ, ចុះថ្ងៃទី៥ កក្កដា ២០១២ ត្រង់កថាខណ្ឌទី៤។ សូមអានផងដែរឯកសារលេខ **E284** សេចក្ដីសម្រេចស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ, កំណត់សម្គាល់លេខ៤ *ខាងដើម* ត្រង់កថាខណ្ឌទី៤៥(i)។ ឯកសារលេខ **E264/1** អនុស្សរណៈ៖ ការកំណត់កាលបរិច្ឆេទរបស់អ្នកជំនាញ Phillip Short និង Elizabeth Becker និងការពន្យារពេលស្ដាប់សក្ខីកម្មសាក្សីពាក់ព័ន្ធនឹងអង្គហេតុរហូតដល់មានសេចក្ដីសម្រេចថ្មីអំពីការបំបែកកិច្ចដំនើរការនីតិវិធីសវនាការ, ចុះថ្ងៃទី២៦ កុម្ភៈ ២០១៣ ត្រង់កថាខណ្ឌទី២។

[6] ឯកសារលេខ E194៖ លំដាប់លំដោយនៃការផ្ដល់សក្ខីកម្មរបស់សាក្សីក្នុងសវនាការបច្ចុប្បន្ននៃសំណុំរឿងលេខ០០២/០២, ចុះថ្ងៃទី១១ ឧសភា ២០១២។

[7] ឯកសារលេខ **E284** សេចក្ដីសម្រេចស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ, កំណត់សម្គាល់លេខ៤ *ខាងដើម* ត្រង់កថាខណ្ឌទី១៥៣ ។

និងរបស់ជនជាប់ចោទ និងរចនាសម្ព័ន្ធផ្នែករដ្ឋបាល ការប្រាស្រ័យទាក់ទងគ្នា និងឃោឃារបស់បក្សកុម្មុយនីស្តកម្ពុជា[8] អង្គជំនុំជម្រះនេះបានគ្រោងផែនការសម្រាប់ការជំនុំជម្រះក្តីនាពេលក្រោយៗទៀត ដោយមិនបានកំណត់អំពីភ័ស្តុតាងដែលត្រូវដាក់ជូនជាថ្មីឡើងវិញ នូវកថាខណ្ឌទាំងឡាយនៃដីកាដំណោះស្រាយ ដែលទោះបីយ៉ាងណាក៏ដោយ ក៏នៅតែជាប់ពាក់ព័ន្ធដែរនោះឡើយ។ ផ្ទុយទៅវិញ ការជំនុំជម្រះក្តីសម្រាប់ពេលអនាគតនឹងលើកឡើងតែអំពីចំណុចបន្ថែមសំខាន់ៗនៃបញ្ហាដែលទាក់ទងនឹងអង្គហេតុដែលពាក់ព័ន្ធនឹងបទចោទប្រកាន់ និងទីតាំងឧក្រិដ្ឋកម្ម ជាពិសេស ដែលកំពុងមានបញ្ហានៅក្នុងសវនាការនីមួយៗតែប៉ុណ្ណោះ[9]។ ហេតុនេះហើយ ការសន្និដ្ឋានយ៉ាងច្បាស់នោះ គឺថាភ័ស្តុតាងមានលក្ខណៈត្រួតគ្នា និងដែលមានស្រាប់ ហើយដែលអាចឲ្យរកបាននៅក្នុងការជំនុំជម្រះក្តីសម្រាប់ពេលអនាគត ដោយហេតុថា ភ័ស្តុតាងទាំងនោះត្រូវបានទទួលយកនៅក្នុងសំណុំរឿងលេខ០០២/០១ រួចហើយ។

៦- ថ្មីៗនេះ ការសន្ទតរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងភាពដែលអាចអនុវត្តបានដោយផ្ទាល់នូវកំណត់ហេតុនៃសំណុំរឿង០០២/០១ ទៅក្នុងសំណុំរឿង០០២/០២ គឺជាក់ស្តែង មាននៅក្នុងអនុស្សរណៈរបស់លោកប្រធាន ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ដែលនៅក្នុងនោះ គាត់បានបដិសេធ មិនព្រមចាត់តាំងអង្គជំនុំជម្រះសាលាដំបូងទីពីរនោះទេ[10]។ ក្នុងអនុស្សរណៈនោះ នៅពេលដែលបានរៀបរាប់ ថាតើហេតុធ្វីបានជាការជួលចៅក្រម និងបុគ្គលិកថ្មី អាចបណ្តាលឲ្យមានការពន្យារពេលនោះ លោកប្រធានបានថ្លែងថា "ខណៈដែលចៅក្រម និងមន្ត្រីច្បាប់ថ្មីទាំងអស់ ត្រូវបានតែងតាំង ឬជ្រើសរើសរួច ពួកគាត់នឹងត្រូវការពេលវេលា ដើម្បីសិក្សាដីកាដំណោះស្រាយ <u>ភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿង</u> នីតិវិធី និង<u>ការជំនុំជម្រះនានាដែលបានធ្វើរហូតមកដល់ បច្ចុប្បន្ននេះ</u>"[11]។ លោកប្រធានក៏

[8] ឯកសារលេខ**E124/7.3** ឧបសម្ព័ន្ធ: បញ្ជីកថាខណ្ឌនិងផ្នែកនៃដីកាដំណោះស្រាយដែលទាក់ទងទៅនឹងសំណុំរឿងលេខ០០២/០១, ដែលត្រូវបានកែប្រែបន្ថែមពីលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសម្បទារបស់អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ(ឯកសារលេខ E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះលើសំណុំរឿងលេខ ០០២/០១ (ឯកសារលេខ E163)។

[9] ឯកសារលេខ **E284** សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ, កំណត់សម្គាល់លេខ៤ *ខាងដើម* ត្រង់កថាខណ្ឌទី ៧១-៧៤។

[10] **E301/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ អនុស្សរណៈរបស់ប្រធានអង្គជំនុំកជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បីជំនុំជម្រះលើការចោទប្រកាន់ដែលមិនទាន់ត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២, ២០ ធ្នូ ២០១៣។

[11] ដដែលដូចមុន ត្រង់កថាខណ្ឌ ៧ (សង្កត់ន័យបន្ថែមដោយ <u>គូសបន្ទាត់ពីក្រោម</u>)។

បានយកមកពិចារណាផងដែរ នូវភាពចាំបាច់ចំពោះចៅក្រមថ្មីសក្តានុពល ក្នុងការអានប្រតិចារឹកទាំងអស់នៅក្នុងសំណុំរឿង០០២/០១ ដោយពុំមានសំណួរថាតើ សក្ខីកម្មនៅក្នុងប្រតិចារឹកទាំងនោះ នឹងក្លាយជាផ្នែកនៃសំណុំរឿង០០២/០២ ដែរ ឬទេ នោះ[12]។

៧- លើសពីនេះ នៅក្នុងអនុស្សរណៈរបស់គាត់ លោកប្រធានបានកត់សម្គាល់អំពីការចាំបាច់ត្រូវឱ្យមានភាពឆាប់រហ័សនៅក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២/០២។ សេចក្តីសម្រេចជាផ្លូវការមួយនៅពេលនេះ ដែលបង្ហាញនូវបំណងមិនច្បាស់របស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីពិចារណាគ្រប់ភ័ស្តុតាងទាំងអស់នៃសំណុំរឿង០០២/០១ ធ្វើជាកំណត់ហេតុនៅក្នុងសំណុំរឿង ០០២/០២ គឺជាវិធីមួយដ៏ឆាប់រហ័សបំផុតដែលត្រូវធ្វើ។

## *ខ. អង្គជំនុំជម្រះត្រូវបន្តអនុវត្តនូវនីតិវិធីរបស់ខ្លួនដែលបានបង្កើតឡើងរួចហើយ ក្នុងការអនុញ្ញាតឱ្យមានការកោះហៅសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ជាថ្មីឡើងវិញ*

៨- ពីមុនមក អង្គជំនុំជម្រះនេះធ្លាប់បានធ្វើការកោះហៅដើមបណ្តឹងរដ្ឋប្បវេណីមកសួរជាថ្មីឡើងវិញ នៅពេលដែលខ្លួនបានរកឃើញថាសកម្មភាពបែបដូច្នោះ គឺដើម្បី "ផលប្រយោជន៍នៃយុត្តិធម៌"[13]។ អង្គជំនុំជម្រះនេះបានរកឃើញថា បទដ្ឋាននៃផលប្រយោជន៍នៃយុត្តិធម៌ នឹងត្រឹមត្រូវទៅបាន កាលណាវាមានការចាំបាច់នៅក្នុងការកោះហៅដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ ឱ្យមកបញ្ជាក់ព័ត៌មានជាថ្មីឡើងវិញបាន[14]។

៩- ក្នុងការរក្សាទុកនូវនីតិវិធីដែលបានបង្កើតឡើងរួចហើយនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា នៅក្នុងដំណើរការលើសំណុំរឿង០០២/០២ អង្គជំនុំជម្រះសាលាដំបូងគួរត្រូវអនុញ្ញាត ឱ្យភាគីនានាធ្វើការបង្ហាញ ដោយមានមូលដ្ឋានទៅតាមករណីនីមួយៗថា សាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១ រួចហើយ គួរត្រូវបានកោះហៅជាថ្មីឡើងវិញ ដើម្បី

---

[12] ដដែលដូចមុន។

[13] **E267/3** សេចក្តីសម្រេចលើសំណើសុំកោះហៅសាជាថ្មីដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 និងសុំឱ្យពិនិត្យឡើងវិញលើបែបបទ ពាក់ព័ន្ធនឹងសក្ខីកម្មស្តីពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី និង សំណើ និង ចម្លើយតបនានា ដែលពាក់ព័ន្ធ (E240, E240/1, E250, E250/1, E267, E267/1 និង E267/2), ២ ឧសភា ២០១៣ ត្រង់កថាខណ្ឌ ២០។

[14] ដដែលដូចមុន ត្រង់ទំព័រទី ១០។

ឲ្យមកផ្តល់សក្ខីកម្មបន្ថែមទៀតនៅក្នុងសំណុំរឿង០០២/០២ លើបញ្ហានានាដែលពាក់ព័ន្ធទៅនឹងវិសាលភាពនៃកិច្ចដំណើរការនីតិវិធីលើកក្រោយនេះ។ ចំពោះវិសាលភាពដែលភាគីណាមួយអាចបង្ហាញជូនអង្គជំនុំជម្រះនេះថា លទ្ធភាពរបស់ខ្លួនក្នុងតាំង សំណួរដេញដោលផ្សេងៗទាក់ទងនឹងសំណុំរឿង០០២/០២ ទៅលើសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ ដែលបានកម្រិតដោយវិសាលភាពនៃសំណុំរឿង០០២/០១នោះ ហើយដែលមានសំណួរក្រោយៗពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០២ ព្រមទាំងមិនបណ្តាលឲ្យមានការពន្យារកិច្ចដំណើរការនីតិវិធីហួសហេតុផងនោះៗ អង្គជំនុំជម្រះសាលាដំបូងអាចនឹងបង្គាប់ឲ្យធ្វើការកោះហៅសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីរូបនោះ ដើម្បីសួរដេញដោលបន្ថែមទៀត។

១០- នីតិវិធីបែបដូច្នេះ គឺមានលក្ខណៈត្រូវគ្នាទៅនឹងវិធាននីតិវិធីអន្តរជាតិ ដែលតុលាការពិសេស ផ្សេងៗបានទទួលយកមកអនុវត្តតាម កាលណាការកោះហៅសាក្សីជាថ្មីឡើងវិញ អាចនឹងកើតឡើងនៅពេលដែលភាគីដាក់សំណើបានបង្ហាញនូវមូលហេតុដ៏ល្អរួចហើយ ដោយយក "គោលបំណងដែលសាក្សីរូបនោះ នឹងត្រូវផ្តល់សក្ខីកម្ម ក៏ដូចជាមូលហេតុនានាហេតុអ្វីបានជាសាក្សីរូបនោះ ពីមុនមិនត្រូវបានគេសួរដេញដោលអំពីបញ្ហាទាំងនោះ" មកពិចារណា[15]។

## *គ. សេចក្តីសម្រេចស្នើសុំ និងនីតិវិធីកោះហៅជាថ្មីឡើងវិញ អាចមិនមានផលប៉ះពាល់ជាអវិជ្ជមានទៅលើសិទ្ធិរបស់មេធាវីការពាក្តីឡើយ*

១១- សេចក្តីសម្រេចដែលបានស្នើសុំស្តីពីការប្រើភ័ស្តុតាងពីសំណុំរឿង០០២/០១ និងដំណើរការនីតិវិធីដែលបានស្នើសុំ ក្នុងការកោះហៅសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីជាថ្មីឡើងវិញនេះ បានលើកកម្ពស់ដល់សិទ្ធិរបស់ជនជាប់ចោទពេញលេញ ក្នុងការតទល់នឹងភ័ស្តុតាងនានាប្រឆាំងនឹង

[15] *រដ្ឋអាជ្ញា ទល់នឹង Édouard Karemera និងគូកន,* សំណុំរឿងលេខ ICTR-98-44-T, សេចក្តីសម្រេចលើញត្តិរបស់ Joseph Nzirorera ស្នើសុំឲ្យកោះហៅសាក្សី BDW របស់អយ្យកាជាថ្មីឡើងវិញ (អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTR), ២៣ កក្កដា ២០០៩ ត្រង់កថាខណ្ឌ ៣។ *រដ្ឋអាជ្ញា ទល់នឹង Radovan Karadžić,* សំណុំរឿងលេខ IT-95-5/18-T, សេចក្តីសម្រេចលើញត្តិរបស់ជនជាប់ចោទស្នើសុំឲ្យកោះហៅ Harry Konings ជាថ្មីឡើងវិញ ដើម្បីសួរដេញដោលសាក្សីរបស់ភាគីបដិបក្ខបន្ថែមទៀត (អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY), ១១ កុម្ភៈ ២០១១ ត្រង់កថាខណ្ឌ ៨។ *រដ្ឋអាជ្ញា ទល់នឹង Ante Gotovina និងគូកន,* សំណុំរឿងលេខ IT-06-90-T, សេចក្តីសម្រេចលើញត្តិរបស់អយ្យកាស្នើសុំឲ្យកោះហៅ Marko Rajčič ជាថ្មីឡើងវិញ (អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY), ២៤ មេសា ២០០៩ ត្រង់កថាខណ្ឌ ១០។

រូបគាត់ ដូចដែលបានចែងនៅក្នុងមាត្រា៣៣ថ្មី និង៣៥ថ្មី(ង) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និង នៅក្នុងវិធាន២១ នៃវិធានផ្ទៃក្នុង។

១២- ការប្រើប្រាស់ភ័ស្តុតាងដែលបានស្នើសុំមានរួចជាស្រេចហើយនៅក្នុងកំណត់ហេតុប្រឆាំងនឹងសហជនជាប់ចោទតែមួយដូចគ្នា នៅក្នុងសំណុំរឿង០០២/០២ គឺតាមវិធីណាក៏ដោយមិនរារាំងដល់ការអនុវត្តសិទ្ធិជាមូលដ្ឋានដោយសេរី និងពេញលេញ ក្នុងការទទួលបាននូវការកាត់សេចក្តីត្រឹមត្រូវនោះទេ។ សិទ្ធិក្នុងការតទល់គ្នានេះ គឺត្រូវបានធានាដោយលិខិតុបករណ៍គតិយុត្តអន្តរជាតិជាច្រើន[16]។ លិខិតុបករណ៍មាន៖ (១)សិទ្ធិរបស់ចុងចោទដេញដោល និងបានដេញដោលសាក្សីនានាដែលប្រឆាំងនឹងរូបគាត់, និង (២)សិទ្ធិក្នុងការបានចូលរួម និងបានសួរដេញដោលសាក្សីតាងនាមចុងចោទ ក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងសាក្សីដែលប្រឆាំងនឹងរូបគាត់ដូច្នោះដែរ[17]។ គោលបំណងសំខាន់នៃសិទ្ធិនេះ គឺធ្វើឲ្យចុងចោទនៅក្នុងរឿងព្រហ្មទណ្ឌ មានលទ្ធភាពអាចធ្វើតេស្តទៅលើទំនុកចិត្តរបស់សាក្សី ឬ ក៏ដាក់ការសង្ស័យទៅលើភាពជឿជាក់របស់គាត់[18]។

១៣- ភ័ស្តុតាងទាំងអស់នៅក្នុងសំណុំរឿង០០២/០១ ដែលសំណើសុំនេះកំពុងស្វែងរកដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២/០២ នោះសិទ្ធិតទល់គ្នារបស់ភាគីនឹងមិនត្រូវបានសម្រុះសម្រួលទេ ដោយហេតុថាភាគីទាំងអស់ត្រូវមានឱកាសរួចហើយ ដើម្បីប្រើប្រាស់សិទ្ធិក្នុងការតទល់គ្នានេះ ជាមួយសាក្សីពាក់ព័ន្ធម្នាក់ៗរួចហើយ។ ជាងនេះទៀត សហជនជាប់ចោទ និងក្រុមមេធាវីរបស់គាត់ ក៏ត្រូវបានផ្តល់ឱកាស

---

[16] អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស, មាត្រា ៦(៣)៖ "បុគ្គលគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌត្រូវមានសិទ្ធិជាអប្បបរមាដូចតទៅ... (ឃ) ដើម្បីនឹងតាំងសំនួរ ឬក្នុងការបានតាំងសំនួរដល់សាក្សីនានាដែលប្រឆាំងនឹងរូបគាត់ និងដើម្បីបានចូលរួម និងបានសួរដេញដោលសាក្សីក្នុងនាមជាចុងចោទ ដោយស្ថិតនៅក្រោមលក្ខខណ្ឌតែមួយដូចគ្នាទៅនឹងសាក្សីដែលប្រឆាំងនឹងរូបគាត់..."។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ, មាត្រា ១៤(៣)៖ "ក្នុងករណីនៃការសម្រេចវិនិច្ឆ័យលើទោសព្រហ្មទណ្ឌណាមួយ ជនជាប់ចោទគ្រប់ៗរូបត្រូវមានសិទ្ធិស្មើៗគ្នាទទួលបាននូវការធានាជាអប្បបរមា ... (ង) ដើម្បីនឹងតាំងសំនួរ ឬក្នុងការបានតាំងសំនួរដល់សាក្សីនានាដែលប្រឆាំងនឹងរូបគាត់ និងដើម្បីបានចូលរួម និងបានសួរដេញដោលសាក្សីក្នុងនាមជាចុងចោទ ដោយស្ថិតនៅក្រោមលក្ខខណ្ឌតែមួយដូចគ្នាទៅនឹងសាក្សីដែលប្រឆាំងនឹងរូបគាត់..."។ អនុសញ្ញាអាមេរិកកាំងស្តីពីសិទ្ធិមនុស្ស, "កតិកាសញ្ញា San Jose, Costa Rica" មាត្រា ៨.២(ច), "សិទ្ធិរបស់មេធាវីការពារក្តីក្នុងការសួរដេញដោលសាក្សីដែលមានវត្តមានក្នុងតុលាការ និងដើម្បីបានទទួលនូវការបង្ហាញខ្លួនរបស់អ្នកជំនាញ ឬបុគ្គលដទៃទៀតដែលអាចនឹងបង្ហាញការពិតលើអង្គហេតុនានា ដូចជាសាក្សីដូច្នោះដែរ"។ *ប្រៀបធៀប* ធម្មនុញ្ញអាហ្វ្រិកកាំង (Banjul) ស្តីពីសិទ្ធិមនុស្ស និង សិទ្ធិពលរដ្ឋ។

[17] អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស, មាត្រា ៦(៣)(ឃ)។

[18] *Windisch ទល់នឹង ប្រទេសអូទ្រីស,* សំណើសុំលេខ 12489/86, សាលក្រម (តុលាការសិទ្ធិមនុស្សអឺរ៉ុប), ២៧ កញ្ញា ១៩៩០ ត្រង់កថាខណ្ឌ ២៨។

ច្រើនសន្លឹកសន្ធាប់ ដើម្បីតវ៉ាចំពោះភ័ស្តុតាងឯកសារទាំងអស់ នៅក្នុងសំណុំរឿង ០០២/០១ តាមរយៈការពិភាក្សាដេញដោលផ្សេងៗ រួមមាន សវនាការលើភ័ស្តុតាងស្តីពីយថាភូត ភាពពាក់ព័ន្ធ និងភាពជឿទុកជាក់បាននៃឯកសារនិមួយៗ និងប្រភេទនៃឯកសារដែលបានកំណត់[19] និងការដាក់សំណើសុំជាលាយលក្ខណ៍អក្សរផ្សេងៗទៀត[20]។ ជាចុងក្រោយ មិនមានការហាមភាគីណាមួយ មិនឲ្យបង្ហាញភ័ស្តុតាង ឬអំណះអំណាងបន្ថែមទៀត ទាក់ទងនឹងតម្លៃភវនីយភាពនៃភ័ស្តុតាងឯកសារដែលបានទទួលយក នៅក្នុងសំណុំរឿង០០២/០១ នៅក្នុងបរិបទនៃបញ្ហាផ្សេងៗនៃសំណុំរឿង០០២/០២ នោះឡើយ។

## *ឃ. សេចក្តីសម្រេចដែលបានស្នើសុំ និងការរំលឹកឡើងវិញអំពីនីតិវិធី អាចធ្វើឲ្យសវនាការប្រកបដោយប្រសិទ្ធភាព និងឆាប់រហ័ស*

១៤- ដោយការកាត់បន្ថយឲ្យបានជាអប្បបរមានូវភាពត្រួតស៊ីគ្នានៃពេលវេលា និងធនធានរបស់អង្គជំនុំជម្រះ តាមរយៈការទទួលយកឡើងវិញលើសពីតម្រូវការនៃកិច្ចដំណើរការនីតិវិធីភ័ស្តុតាង នោះសេចក្តីសម្រេច និងការរំលឹកឡើងវិញអំពីនីតិវិធីលើកកម្ពស់ទាំងប្រសិទ្ធភាព និងភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២។ ដូចអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់នាពេលថ្មីៗនេះថា "ចៅក្រមត្រូវមានកាតព្វកិច្ចយល់ដឹងអំពីប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធីនៅគ្រប់ពេលវេលាទាំងអស់"[21]។ លើសពីនេះ តម្រូវការនៃវិធីសាស្ត្រគ្រប់គ្រងរឿងក្តី កាន់តែប្រសើរឡើង និងដែលស៊ីសង្វាក់គ្នាទាំងស្រុងទៅនឹងសិទ្ធិទទួលបានសវនាការត្រឹមត្រូវយុត្តិធម៌ គឺទទួលបានអាណត្តិជាក់លាក់ ដោយបាយការណ៍ចុះខែធ្នូ ឆ្នាំ២០១៣ របស់គណៈកម្មាធិការប្រឹក្សាស្តីពីបញ្ហារដ្ឋបាល

[19] សូមមើលកិច្ចដំណើរការនីតិវិធី ថ្ងៃទី១៦-១៩ ខែមករា ឆ្នាំ២០១២; ២៣-២៥ មករា ២០១២; ១, ២, ៦, ៨, ៩, ១៣-១៦ កុម្ភៈ ២០១២; ១២-១៥ មីនា ២០១២; ២១-៣១ មករា ២០១៣; ៥ កុម្ភៈ ២០១៣; ២៤-២៧ មិថុនា ២០១៣ និង ៨-៩ កក្កដា ២០១៣។

[20] សូមមើល ឧទាហរណ៍ ឯកសារ **E131/6** សេចក្តីជំទាស់មិនទទួលយកបញ្ជីឯកសារ ដែលដាក់ដោយភាគីផ្សេងទៀតសម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង, ២៥ វិច្ឆិកា ២០១១។ **E131/1/11** សេចក្តីជំទាស់មិនទទួលយកបញ្ជីឯកសារសេសសល់ដែលដាក់ដោយភាគីផ្សេងទៀតសម្រាប់ការជំនុំជម្រះដំណាក់កាលដំបូងទាំងបួន, ៥ មករា ២០១២។ **E223/2/8/1** ឧបសម្ព័ន្ធបន្ថែមពាក់ព័ន្ធនឹងការជំទាស់ទៅនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនិងប្រតិចារឹកនានា, ២៩ មេសា ២០១៣។ **E131/1/12** ការជំទាស់ទៅនឹងឯកសារ និង សារណាបន្ថែមដោយអនុលោមតាមវិធាន ៩២, ៥ មករា ២០១២។ **E131/1/9** ការជំទាស់ ការកត់សម្គាល់ និងការជូនដំណឹងទាក់ទងនឹងឯកសារផ្សេងៗដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ១៤ វិច្ឆិកា ២០១១។

[21] **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២, ២៥ វិច្ឆិកា ២០១៣ ត្រង់កថាខណ្ឌ៧៥។

និងថវិកា (ACABQ) ដែលបានដាក់ជូនគណៈកម្មាធិការទីប្រាំនៃមហាសន្និបាតអង្គការសហប្រជាជាតិពាក់ព័ន្ធទៅនឹងការផ្ដល់ហិរញ្ញវត្ថុដល់ អ.វ.ត.ក។ ជាលក្ខខណ្ឌសម្រាប់លទ្ធភាពទទួលបានជំនួយថវិកា របាយការណ៍ ACABQ នេះ ទាមទារឲ្យ "បញ្ចប់សំណុំរឿងទាំងបីដែលនៅសល់ឲ្យទាន់ពេលវេលា ព្រមទាំងការអភិវឌ្ឍន៍ និងការអនុវត្តវិធីសាស្ត្រគ្រប់គ្រងសំណុំរឿងប្រកបដោយវិន័យ ដូចជាឱកាសចូលពិនិត្យប្រាក់ជំនួយ"[22]។ តាមការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ការអនុវត្តភារកិច្ចនេះត្រូវធានាឲ្យមានសេចក្ដីសម្រេចដែលបានស្នើសុំ ដែលអាចលើកកម្ពស់សវនាការឲ្យមានប្រសិទ្ធភាព និងឆាប់រហ័សស្របគ្នាទាំងស្រុងទៅនឹងសិទ្ធិមេធាវីការពារក្ដី។

១៥- អាស្រ័យដូចមូលហេតុជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះ ៖

ក. **កំណត់ថា** ភស្តុតាងទាំងអស់ដែលបានទទួលយកនៅក្នុងសំណុំរឿង០០២/០១ នឹងអាចឲ្យរកបាន និងត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង០០២/០២ ដោយស្វ័យប្រវត្តិ។

ខ. **ណែនាំឲ្យ** អង្គភាពកំណត់ហេតុ និងបណ្ណសារ ចាត់ដាក់លេខ E3 ដូចគ្នា លើគ្រប់ភស្តុតាងទាំងអស់នេះ ដែលបានពីសំណុំរឿង០០២/០១ សម្រាប់ប្រើប្រាស់ក្នុងសំណុំរឿង ០០២/០២; និង

គ. **សម្រេច** លើបញ្ហានេះឲ្យបានឆាប់តាមដែលអាចធ្វើបាន ដើម្បីឲ្យភាគីទាំងអស់បានជួយអង្គជំនុំជម្រះសាលាដំបូង លើបញ្ហាផ្សេងៗទៀតទាក់ទងនឹងវិសាលភាព និងកាលបរិច្ឆេទនៃការចាប់ផ្ដើមសំណុំរឿង០០២/០២ ដោយឈរលើមូលដ្ឋាននៃការជូនដំណឹងឲ្យបានពេញលេញនូវកាលបរិច្ឆេទសម្រាប់សវនាការនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ ខាងមុខនេះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | |

[22] សំណើសុំការផ្ដល់ជំនួយដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, UN Doc. A/68/7/Add.12, របាយការណ៍ (គណៈកម្មាធិការប្រឹក្សាស្ដីពីបញ្ហារដ្ឋបាល និងថវិកា) ៤ ធ្នូ ២០១៣ ត្រង់កថាខណ្ឌ២៣។